**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ១៨ "គ"ក្រ៩
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ: ១៦៤៤
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ: ១២៤៩
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ: ៣០៤២
ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈនៅសាលសវនាការទី២នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៩ និង០០នាទីព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៤៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] លុច ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ ទទួលផ្ញើអីវ៉ាន់ទៅក្រៅប្រទេសលក្ខណៈគ្រួសារ មានទីកន្លែងកំណើត កើតនៅ[redacted] ខេត្តពោធិ៍សាត់ មានទីលំនៅមុនពេលឃាត់ខ្លួននៅស្នាក់នៅផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពេជ្រ"រស់" ម្តាយឈ្មោះ [redacted] នាង"រស់" ប្រពន្ធឈ្មោះ ឈិត សុធា"រស់" មានកូន ០១នាក់ ជា **នីតិជន**។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ **២៧៦៣"ដ" ដ.ឃ.ដ** ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដោយមានលោក [redacted] ជាមេធាវីការសិទ្ធិឱ្យជនជាប់ចោទ។

២-ឈ្មោះ [redacted] ធី ([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ កំរិតវប្បធម៌ថ្នាក់ទី៥ មានទីកន្លែងកំណើតនៅភូមិ[redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចន "ស្លាប់" ម្តាយឈ្មោះ [redacted] សាវ៉ន "ស្លាប់" ជា **នីតិជន** (គេចខ្លួន)។

-ដោយមានលោកស្រី [redacted] ជាមេធាវីការសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ: **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៥ និង ០០នាទីរសៀល ក្រុមមន្ត្រី X-Ray ប្រចាំនៅក្រុមហ៊ុន ឌីអិចអិល អិចប្រេស ខេមបូឌា អិលធីឌី DHL Express(Cambodia)Ltd សាខាព្រៃទា បានត្រួតពិនិត្យ និងស្កែនកញ្ចប់បញ្ញើចំនួន ០១កញ្ចប់ មានលេខកូដ WAYBILL 1835241111 ជាប្រភេទបញ្ញើបិទជិត មានទម្ងន់សរុប ២,១គីឡូក្រាម (ពីរក្បៀសមួយ)គីឡូក្រាម សង្ស័យលាក់បង្កប់នូវសារធាតុញៀនខុសច្បាប់ ផ្ញើចេញពីក្រុមហ៊ុន ឌីអិចអិល អិលធីឌី DHL Express(Cambodia)Ltd ប្រទេសកម្ពុជា ទៅកាន់ប្រទេស នូវែលសេឡង់ ដោយមានអ្នកផ្ញើឈ្មោះ [redacted] លុច ដែលមានអាសយដ្ឋានស្ថិតនៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងអ្នកទទួលឈ្មោះ [redacted] XU មានអាសយដ្ឋាន ២០B BRONZEWING TERRACE UNSWORTH HEIGHTS AUCKLAND NEW ZEALAND ទូរស័ព្ទលេខ +640 226467043។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០នាទី កម្លាំងការងារចម្រុះ បានយកកញ្ចប់បញ្ញើខាងលើទៅត្រួតពិនិត្យឃើញមាន៖ អាវយឺត, ស្បែកជើង, កន្សែង និងប្រអប់ដាក់វត្ថុអនុស្សាវរីយ៍ ពណ៌លឿងចំនួន ០១ប្រអប់ ដោយនៅក្នុងប្រអប់នោះមានវត្ថុអនុស្សាវរីយ៍រូបអង្គរវត្ត និងបានគាស់បាតចំហៀងនៃប្រាសាទអង្គរវត្តនោះមានឃើញក្រាមពណ៌ ស ទម្ងន់ ១០៤,៧០(មួយរយបួនក្បៀសចិតសិប)ក្រាម។ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ កម្លាំងជំនាញនាយកដ្ឋានសន្តិសុខផ្ទៃក្នុង សហការណ៍ជាមួយកម្លាំងអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ក៏បានចុះឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] លុច នៅចំណុចផ្ទះលេខ ២៩ ផ្លូវលេខ E-4 បុរីប៉េងហួន EMERAL សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយជនជាប់ចោទបានឆ្លើយថា កញ្ចប់បញ្ញើខាងលើខ្លួនទទួលពីឈ្មោះ [redacted] នី ភេទស្រី បានយកមកផ្ញើខ្លួនចេញទៅប្រទេស នូវែលសេឡង់។ សមត្ថកិច្ចបានកសាងសំណុំរឿង និងវត្ថុតាង បញ្ជូនទៅអយ្យការអមសាលាដំបូងរាជភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

-**បានឃើញ** របាយការណ៍លេខ **០៥២ ស.ណ** ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១២៦៧ អ.យ.គ** ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៤៥១ "ដ"ដ.ច.ន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **២៩៣៩ អ.យ.គ** ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យរក្សាជនត្រូវចោទក្នុងឃុំបណ្ដោះអាសន្នលេខ **៦៤៨៦"ដ"ដ.ឃ.ដ** ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៩១៦"ដ"ដ.ដ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លុច បានឆ្លើយថា ខ្លួនជាអ្នកប្រកបមុខរបរ ជាអ្នកទទួលបញ្ញើទៅក្រៅប្រទេសជាលក្ខណ:គ្រួសារ ដោយខ្លួនទទួលបញ្ញើពីប្រទេសកម្ពុជា ផ្ញើទៅក្រៅប្រទេស ហើយបញ្ញើញ៉ើកញ្ចប់នោះគឺទៅប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក ។ ការទទួលបញ្ញើពីអតិថិជន គឺខ្លួនបានបង្កើតគេហទំព័រ(Facebook Pape) ឈ្មោះ Gofast Express ហើយទីតាំងដែលខ្លួនទទួលបញ្ញើពីអតិថិជន គឺផ្ញើនៅផ្ទះដែលខ្លួនស្នាក់នៅតែម្ដង ប៉ុន្តែនៅផ្ទះរបស់ខ្លួន

ពុំមានលើកផ្ដាកអ្វីនោះទេ ហើយក៏ពុំមានចុះបញ្ជីត្រឹមត្រូវដែរ។ ក្រោយពីខ្លួនបានទទួលបញ្ញើពីអតិថិជនរួចមក ខ្លួនក៏យកបញ្ញើរបស់អតិថិជនទៅឱ្យក្រុមហ៊ុន **ហ្វារិក វើលវាយ អ៊ិចប្រេស** (FAREX WORLDWIDE EXPRESS) ហើយក្រុមហ៊ុននេះបានយកទៅផ្ញើបន្តឱ្យក្រុមហ៊ុន ឌីអិចអិល កម្ពុជា (DHL CAMBODIA) បន្តទៀត។

កាលពីថ្ងៃទី២៨, ២៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១០ព្រឹក មានស្ត្រីម្នាក់មិនស្គាល់ឈ្មោះ បានតេទូរស័ព្ទលេខ(០៩៨ ២២១៣១៥) មកខ្លួន ដើម្បីសួរនាំអំពីការផ្ញើអីវ៉ាន់ចេញទៅប្រទេសក្រៅ ដោយបានសួរទីតាំងរបស់ខ្លួនដែលទទួលបញ្ញើ ហើយខ្លួនក៏បានប្រាប់ថា ខ្លួនស្នាក់នៅបុរីប៉េងហួត លើផ្លូវម៉ុងរិទ្ធី ហើយស្ត្រីនោះក៏បានឆ្លើយថា គាត់ស្នាក់នៅប៉េងហួតដែរ គឺនៅបុរីប៉េងហួតបឹងស្នោ គម្រោងទី៦ ចាំគាត់យកអីវ៉ាន់ទៅឱ្យដោយផ្ទាល់ដៃ។ លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្ត្រីម្នាក់នោះបានទូរស័ព្ទមកខ្លួនដោយប្រាប់ថា នឹងយកអីវ៉ាន់ទៅដាក់ផ្ញើហើយ តែការពិតគាត់យល់ច្រឡំទីតាំង ដោយសារខ្លួនស្នាក់នៅបុរីប៉េងហួត ផ្លូវម៉ុងរិទ្ធី មិនមែននៅបឹងស្នោដូចការយល់ឃើញរបស់គាត់ឡើយ។ លុះម៉ោងប្រហែល ៩ព្រឹក ស្ត្រីរូបនោះបានទូរស័ព្ទមកខ្លួនឱ្យទៅយកអីវ៉ាន់នៅម្ដុំបឹងត្របែក ហើយខ្លួនក៏បានឱ្យអ្នករត់កង់បីឈ្មោះ រតនៈ ទៅយកគាត់ និងអីវ៉ាន់របស់គាត់។ ក្រោយមកម៉ោងប្រហែល ១១ព្រឹក ឈ្មោះ រតនៈ បានដឹកស្ត្រីម្នាក់នោះមកដល់ផ្ទះរបស់ខ្លួន ហើយខ្លួនក៏បានហៅគាត់ឱ្យអង្គុយលេងនៅកន្លែងទទួលភ្ញៀវ រួចខ្លួនក៏បានយកអីវ៉ាន់របស់គាត់ទៅថ្លឹងរួមទាំងកេះក្រដាស់នោះផង ទម្ងន់សរុបប្រហែល ១,៧៥គីឡូក្រាម។ លុះពេលថ្លឹងរួចហើយ ខ្លួនក៏បានបើកកេះក្រដាស់នោះដើម្បីមើលអីវ៉ាន់ជាក់ស្ដែង។ ក្រោយពេលបើករួចមកក៏ឃើញមាន អាវយឺតចំនួន ០១(មួយ) កន្សែងបង់កចំនួន ០១(មួយ) ស្បែកជើងផ្ទាត់ ០១(មួយ)គូរ រូបចម្លាក់បាយ័នចំនួន ០១(មួយ) និងរូបចម្លាក់អង្គរវត្តចំនួន ០១(មួយ) ហើយពេលនោះខ្លួនពុំបានគាស់មើលអីវ៉ាន់នោះឱ្យបានល្អិតល្អន់ទេ ពីព្រោះខ្លាចខូចអីវ៉ាន់។ បន្ទាប់មកខ្លួនបានសរសេរវិក័យបត្រដោយបានសរសេរវាយមុខអីវ៉ាន់នីមួយៗ ចូលក្នុងវិក័យបត្រនោះ ដោយគិតតម្លៃចំនួន ០២(ពីរ)គីឡូក្រាម តម្លៃផ្ញើជាប្រាក់ចំនួន ១១៥(មួយរយដប់ប្រាំ)ដុល្លារអាមេរិក ហើយស្ត្រីនោះបានប្រាប់ខ្លួនឱ្យដាក់ឈ្មោះ ដាណេ ជាអ្នកផ្ញើ ហើយខ្លួនក៏សរសេរឈ្មោះ ដាណេ នៅក្នុងវិក័យបត្រនោះ និងដាក់លេខទូរស័ព្ទដែលគាត់ប្រើនោះ(០៩៨ ២២១៣១៥) ចូលទៅក្នុងវិក័យបត្រនោះដែរ និងមានឈ្មោះអ្នកទទួលឈ្មោះ [redacted] XU មានអាសយដ្ឋាននៅប្រទេស NEW ZEALAND ដោយប្រើលេខទូរស័ព្ទ +៦៤ ០២២ ៦៤៦៧០៤៣ ។ បន្ទាប់ពីសរសេរវិក័យបត្ររួចហើយ ស្ត្រីម្នាក់នោះបានប្រគល់សាច់ប្រាក់មកឱ្យខ្លួនចំនួន ១១៥(មួយរយដប់ប្រាំ)ដុល្លារអាមេរិក ហើយខ្លួនបានឱ្យវិក័យបត្រច្បាប់ដើមមួយច្បាប់ទៅគាត់ និងទុកច្បាប់ចម្លងនៅនឹងខ្លួនផ្ទាល់។ ក្រោយពីបានទទួលប្រាក់រួច ខ្លួនបានឱ្យស្ត្រីម្នាក់នោះភ្ជាប់ TELEGRAM មកលេខទូរស័ព្ទខ្លួន ០៨៦ ៨៨៤ ៨៨៩ ក្រោយពីស្ត្រីនោះភ្ជាប់ TELEGRAM មកលេខទូរស័ព្ទខ្លួនផ្ទាល់ ក្រោយពេលស្ត្រីនោះបានភ្ជាប់កម្មវិធីរួចហើយ ខ្លួនបានឃើញលេខ TELEGRAM របស់គាត់ឈ្មោះ CHANNY ២០៤៣៨ បន្ទាប់មកខ្លួនក៏បានថតអីវ៉ាន់បានទទួលពីគាត់ រួចផ្ញើឱ្យគាត់តាម TELEGRAM តែម្ដង។ ក្រោយពីបានទទួលអីវ៉ាន់រួចឈ្មោះ រតនៈ ជាអ្នកជូនគាត់ទៅតាមរយៈម៉ូតូកង់បីដដែល។

បន្ទាប់មកខ្លួនបានទាក់ទងទៅបុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន **ហ្វារិក វើលវាយ អ៊ិចប្រេស** (FAREX WORLD WIDE EXPRESS) ឈ្មោះ [redacted] ធឿន តាមរយៈតេឡេក្រាមជាសំឡេង ដើម្បីឱ្យគាត់ទទួលអីវ៉ាន់ពីខ្លួន ហើយពេលនោះឈ្មោះ [redacted] ធឿន បានប្រាប់ថា ចាំបាយហើយចាំឱ្យភ្នាក់ងារមកទទួល។ លុះដល់ម៉ោងប្រហែល ០២រសៀល បុគ្គលិកក្រុមហ៊ុន **ហ្វារិក វើលវាយ អ៊ិចប្រេស**(FAREX WORLDWIDE EXPRESS) បានទទួលអីវ៉ាន់ពីខ្លួននៅផ្ទះរបស់ខ្លួនផ្ទាល់ ដោយពេលនោះបានប្រគល់កេះអីវ៉ាន់នោះទៅឱ្យបុគ្គលិកផ្នែកដឹកជញ្ជូន ដោយពេលនោះបុគ្គលិកក៏បានពិនិត្យមើលអីវ៉ាន់ផ្នែកខាងក្រៅ ពេលគាត់មើលរួចខ្លួនក៏បានថតរូបគាត់ រួចផ្ញើទៅឱ្យឈ្មោះ [redacted] ធឿន តាមរយៈតេឡេក្រាមដដែលដើម្បីបញ្ជាក់ថាមានបុគ្គលិកគាត់បានមកទទួលអីវ៉ាន់ពីខ្លួនហើយ។ លុះប្រហែលម៉ោង ៤រសៀល នាថ្ងៃខែឆ្នាំដដែល ឈ្មោះ[redacted] ធឿន បាន



Scanned with CamScanner

ផ្ញើបង្កាន់ដៃរបស់ក្រុមហ៊ុន DHL មកឱ្យខ្លួន ដោយនៅក្នុងបង្កាន់ដៃនោះមានលេខកូដសម្រាប់តាមដានអីវ៉ាន់ លុះប្រហែលម៉ោង ៥ល្ងាច ខ្លួនក៏បានផ្ញើបន្តទៅតេឡេក្រាមឈ្មោះ [redacted] NY ដែលជាម្ចាស់អីវ៉ាន់។

នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៩ព្រឹក ខ្លួនកំពុងស្នាក់នៅក្នុងផ្ទះ ពេលនោះក៏មានសមត្ថកិច្ចមកដល់ផ្ទះ ហើយបានសួរនាំខ្លួនអំពីការផ្ញើអីវ៉ាន់ខាងលើ បន្ទាប់មកក៏ហៅខ្លួនឱ្យទៅឆ្លើយបំភ្លឺនៅនាយកដ្ឋានសន្តិសុខផ្ទៃក្នុង ហើយខ្លួនក៏បានជិះរថយន្តម៉ាក RANG ROVER ពណ៌ស ឆ្នាំ២០១៤ ពាក់ផ្លាកលេខកម្ពុជា H.S.2021 ទៅកាន់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង លុះទៅដល់ទីនោះសមត្ថកិច្ចបានសួរចម្លើយខ្លួន និងបានបង្ហាញប្រអប់កញ្ចប់បញ្ញើឱ្យខ្លួនឃើញទៀតផង រួចសមត្ថកិច្ចបានថតរូបខ្លួនជាមួយនឹងប្រអប់អីវ៉ាន់នោះ។ ក្រោយសមត្ថកិច្ចបានសុំការអនុញ្ញាតទៅធ្វើការឆែកឆេរនៅទីតាំងផ្ទះរបស់ខ្លួន និងខុនដូរបស់ខ្លួនមួយកន្លែងទៀត ប៉ុន្តែឆែកឆេរមិនឃើញមានរបស់ខុសច្បាប់នោះទេ ហើយសមត្ថកិច្ចក៏នាំខ្លួនមកនាយកដ្ឋានសន្តិសុខផ្ទៃក្នុងវិញ និងបានធ្វើការឃាត់ខ្លួន និងដកហូតសម្ភារៈមួយចំនួនដែលខ្លួនបានរៀបរាប់នៅក្នុងកំណត់ហេតុសួរចម្លើយនៅដំណាក់កាលអយ្យការ។ ខ្លួនមិនដឹងនៅក្នុងអីវ៉ាន់របស់ភ្ញៀវនោះមានផ្ទុកគ្រឿងញៀនទេ ដោយសារពេលទទួលពីភ្ញៀវ ខ្លួនមិនបានឆែកឆេរដល់សភាពខាងក្នុងអីវ៉ាន់នោះទេ ពីព្រោះខ្លាចខូចខាតដល់អីវ៉ាន់ភ្ញៀវ និងមិនមានឧបករណ៍សម្រាប់ស្កេនមើលខាងក្នុងឱ្យបានត្រឹមត្រូវនោះទេ។ ទើបដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ ទើបសមត្ថ-កិច្ចបានហៅមើលជាក់ស្តែង ក្នុងការបើកគាស់រូបចម្លាក់អង្គរវត្តផ្នែកមុខតួប្រាសាទដែលមានបន្ទះនាឡិកា បិទនៅលើនោះចេញមកក៏ឃើញមានគ្រឿងញៀនផ្ទុកនៅក្នុងនោះ ដែលសមត្ថកិច្ចប្រាប់ថា ជាប្រភេទ មេតំហ្វេតាមីន។

ចំពោះរថយន្តម៉ាក RANG ROVER ពណ៌ស ឆ្នាំ២០១៤ ពាក់ផ្លាកលេខកម្ពុជា H.S.2021 ដែលសមត្ថកិច្ចបានដកហូតនោះ គឺជារបស់ខ្លួនទិញយកមកសម្រាប់ជួលឱ្យគេ ហើយពេលទំនេរពីជួលរថយន្តនេះ គឺខ្លួនបានយកទៅដឹកប្រពន្ធ និងកូនដើរលេងប៉ុណ្ណោះ មិនដែលបានយកទៅដឹកអីវ៉ាន់ ឬធ្វើសកម្មភាពក្នុងការដឹកជញ្ជូនអីវ៉ាន់ភ្ញៀវឡើយ។ រថយន្តនេះគឺទិញបង់រំលស់ពីក្រុមហ៊ុន **ឆាយលីស រ៉ូយ៉ាល់ ហ្វាយនែន ម.ក** ជាមួយប្រពន្ធ ក្នុងគោលបំណងជួល និងជិះជាលក្ខណៈគ្រួសារ។

ខ្លួនធ្លាប់ទទួលបញ្ញើពីឈ្មោះ [redacted] NY តែម្តងគត់ គឺនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និងមិនដែលមានទំនាក់ទំនងនឹងគ្នាពីមុនមកទេ។

-សាក្សីឈ្មោះ [redacted] ឈ្នោត បានឆ្លើយថា ខ្លួនជាបុគ្គលិកផ្នែកដឹកជញ្ជូនរបស់ក្រុមហ៊ុន ហ្វារិក(FAREX) ដែលជាក្រុមហ៊ុនទទួលផ្ញើអីវ៉ាន់ទៅក្រៅប្រទេស ដោយបានធ្វើការងាររយៈពេល ០២ឆ្នាំមកហើយ។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៤ និង ០០នាទី ខាងផ្នែកលក់របស់ក្រុមហ៊ុនបានឱ្យខ្លួនទៅទទួលអីវ៉ាន់ពីឈ្មោះ [redacted] លុច ចំនួន ០១(មួយ)កញ្ចប់ ហើយខ្លួនក៏បានទៅជួបឈ្មោះ [redacted] លុច និងបានទទួលកញ្ចប់បញ្ញើដែលមានលេខកូដ WAYBILL 1835241111 ពីគាត់ ពេលនោះគាត់បានបើកបង្ហាញឱ្យមើលឃើញមាន កន្សែងចំនួន ០២ ស្បែកជើងស្រី ០១គូ និងរូបចម្លាក់ប្រាសាទអង្គរវត្ត ពណ៌ទឹកប្រាក់ចំនួន ០១ និងបន្ទោងឈើចំនួន ០១បន្ទះ។ លុះពេលបានអីវ៉ាន់រួចហើយ ខ្លួនបានយកទៅប្រគល់ឱ្យបុគ្គលិកក្រុមហ៊ុន ឌីអែកអ៊ិល សាខាព្រៃទា។ ពេលប្រគល់អីវ៉ាន់រួច ខ្លួនក៏ត្រឡប់មកក្រុមហ៊ុន ហ្វារិកវិញ។ កន្លងមកឈ្មោះ [redacted] លុច បានផ្ញើអីវ៉ាន់តាមរយៈក្រុមហ៊ុន ហ្វារិក ជារៀងរាល់សប្តាហ៍ ហើយខ្លួនធ្លាប់បានក្រុមហ៊ុន ឱ្យទៅទទួលអីវ៉ាន់ពីឈ្មោះ ពេជ្រ លុច ចំនួន ០៣ដងដែរ ក្រៅពីនោះខ្លួនពុំដឹងទេ។

-សាក្សីឈ្មោះ [redacted] សុធា បានឆ្លើយថា ក្នុងឆ្នាំ២០២១ ខ្លួន និងគ្រួសារបានប្រកបមុខរបរ ទទួលផ្ញើឥវ៉ាន់ទៅក្រៅប្រទេស ជូនអតិថិជន ដោយធ្វើជាលក្ខណៈគ្រួសារ ការផ្ញើអីវ៉ាន់ទាំងអស់របស់អតិថិជន ខ្លួនពុំមានអាជ្ញាប័ណ្ណទេ។ រាល់ការទទួលផ្ញើអីវ៉ាន់ពីអតិថិជនទាំងអស់ គឺខ្លួនមានហ្វេសប៊ុកផេកឈ្មោះ GO FAST EXPRESS និងមានលេខទូរស័ព្ទ ០៩៩ ៨៨៤ ៨៨៩ និងលេខ ០៨៦ ៨៨៤ ៨៨៩ សម្រាប់ទទួលការផ្ញើអីវ៉ាន់។ អីវ៉ាន់ភាគច្រើនដែលខ្លួនទទួលផ្ញើទៅក្រៅប្រទេស មានតែពីរប្រទេស គឺប្រទេសអាមេរិក និងប្រទេសអូស្ត្រាលី។ អីវ៉ាន់ដែលទទួលផ្ញើពីអតិថិជនច្រើនជារបស់

ញ៉ាំ(ត្រីងៀត ប្រហុក) និងជាសម្ភារៈប្រើប្រាស់(សម្លៀកបំពាក់ កាបូបផ្សេងៗ)។ ក្រៅពីមុខរបរផ្ញើអីវ៉ាន់ទៅក្រៅប្រទេស ខ្លួនក៏មានមុខរបរមួយទៀត គឺប្រធានក្រុមហ៊ុន SKS ដែលនាំចូលឡា និងស្និតខ្មៅ។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ មានស្ត្រីជនជាតិខ្មែរម្នាក់ បានមកទំនាក់ទំនងមកលេខទូរស័ព្ទដៃដែលខ្លួនដាក់នៅលើហ្វេសប៊ុកផេករបស់ខ្លួន ហើយស្ត្រីនោះបានយកលេខទូរស័ព្ទ ០៩៨ ២២១ ៣១៥ ទំនាក់ទំនងមកខ្លួនលេខ ០៨៦ ៨៨៤ ៨៨៩ ស្ត្រីនោះបានសួរនាំថា កន្លែងផ្ញើអីវ៉ាន់ទៅស្រុកក្រៅមែន ខ្លួនបានឆ្លើយប្រាប់ថា នឹងហើយបងកន្លែងនឹងផ្ញើអីវ៉ាន់ស្រុកក្រៅ ហើយបងចង់ផ្ញើអីវ៉ាន់អីគេដែរ ហើយចង់ផ្ញើទៅប្រទេសណា ស្ត្រីម្នាក់នោះឆ្លើយថា ទៅក្រៅប្រទេសក្មួយវត្ថុអនុស្សាវរីយ៍ ខ្លួនសួរថា តើអីវ៉ាន់ដែលផ្ញើប៉ុន្មានគីឡូ ស្ត្រីនោះឆ្លើយថា មួយគីឡូជាង ហើយគាត់បានសួរថា តម្លៃផ្ញើអស់ប៉ុន្មាន ខ្លួនប្រាប់គាត់ថា អីវ៉ាន់ជាងមួយគីឡូក្រាមអញ្ចឹង ខាងក្រុមហ៊ុន អេក មិល គេគិតទម្ងន់ ២គីឡូក្រាមហើយអញ្ចឹងតម្លៃគឺ ១៣០(មួយរយសាមសិប)ដុល្លារអាមេរិក ស្ត្រីក៏បានប្រាប់ថា គាត់រកទិញអីវ៉ាន់ឱ្យគេសិន។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានឃើញឈ្មោះ ពេជ្រ លុច បានទំនាក់ទំនងជាមួយអតិថិជនម្នាក់ដែលគាត់ប្រាប់ថា ចង់ផ្ញើអីវ៉ាន់ ហើយប្តីខ្លួនបាននិយាយថា នៅប៉េងហួតហើយគាត់និយាយថា ចាំគាត់មកខ្លួនឯងដោយសារនៅជិតគ្នា ហើយប្តីខ្លួននិយាយថា បងច្រឡំហើយខ្លួននៅប៉េងហួតម៉ុងឫទ្ធី មិនមែននៅ ប៉េងហួត បឹងស្នោទេ។ បន្ទាប់ពីប្តីខ្លួននិយាយជាមួយអតិថិជននេះចប់ ខ្លួនក៏ឡើងទៅលើផ្ទះបាត់។ បន្ទាប់មកខ្លួនចុះមកក្រោមវិញ ក៏ឃើញអ្នករត់កង់បីឈ្មោះ រតនៈ បានដឹកស្ត្រីម្នាក់នោះដែលគាត់ចង់ផ្ញើអីវ៉ាន់ទៅក្រៅប្រទេសឱ្យក្មួយនៅញូហ្ស៊ីលែន ហើយប្តីរបស់ខ្លួនក៏បានពិនិត្យឥវ៉ាន់ឃើញមាន របស់ប្រាសាទអង្គរវត្ត និងរូបបាយ័ន្ត (ប៉ុន្តែគាត់ពិនិត្យតែខាងក្រៅប៉ុណ្ណោះ ព្រោះមើលឃើញតែពីខាងក្រៅ ហើយក៏មិនហ៊ានហែកដែលខ្លាចខូចខាតអីវ៉ាន់ភ្ញៀវ។ បន្ទាប់មកប្តីរបស់ខ្លួនក៏សរសេរវិក័យបត្រទូទាត់ប្រាក់ឱ្យទៅស្ត្រីម្នាក់នោះតែម្តង។ រួចមកប្តីរបស់របស់ខ្លួនបានទំនាក់ទំនងទៅទៅក្រុមហ៊ុន ហ្វារិក ឱ្យមកទទួលឥវ៉ាន់។ ស្ត្រីនោះមានភិនភាគរាងស្គម កំពស់ប្រហែល ១,៦០សង់ទីម៉ែត្រ។

អតិថិជនយកអីវ៉ាន់មកផ្ញើម្តងៗ ប្តីខ្លួនតែងតែឆែកឆេរនៅលើអីវ៉ាន់ ប៉ុន្តែមិនបានឆែកឆេរ ឬគាស់មើលនៅខាងក្នុងនោះទេ ពីព្រោះខ្លាចខូចអីវ៉ាន់របស់ភ្ញៀវ ហើយជាក់ស្តែងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ គឺប្តីខ្លួនបានទទួលអីវ៉ាន់ពីស្ត្រីម្នាក់ដែលមានឥវ៉ាន់ដូចរៀបរាប់ខាងលើ ថ្ងៃនោះគឺប្តីខ្លួនបានត្រឹមតែពិនិត្យមើលមានអ្វីនៅក្នុងប្រអប់នោះ ប៉ុន្តែមិនបានគាស់មើលនៅក្នុងផ្នែកខាងក្នុងនោះទេ ទើបបណ្តាលឱ្យមានបញ្ហាបែបនេះ។ ខ្លួនសូមបញ្ជាក់ថា ប្តីខ្លួនទើបតែផ្ញើអីវ៉ាន់របស់ភ្ញៀវទៅប្រទេស ញូហ្ស៊ីលែន ជាលើកទីមួយប៉ុណ្ណោះ ហើយក៏មានបញ្ហាតែម្តង។ រូបថតដែលលើកបង្ហាញនេះពិតជាស្ត្រីដែលយកអីវ៉ាន់មកផ្ញើឱ្យប្តីខ្លួន ហើយខ្លួនមិនដែលស្គាល់គាត់ពីមុនទេ។

-សាក្សីឈ្មោះ [redacted] រតនៈ បានឆ្លើយថា ខ្លួនមានមុខរបរ ជាអ្នករត់កង់បី ដោយប្រកបរបរនេះបានរយៈពេល ៤(បួន)ឆ្នាំហើយ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] លុច តាមរយៈប្អូនស្រីរបស់គាត់។ កន្លងមកខ្លួនធ្លាប់បានទៅដឹក និងទទួលភ្ញៀវដែលមកផ្ញើអីវ៉ាន់តាមរយៈឈ្មោះ [redacted] លុច បានចំនួន ០៤(បួន)ដង។ ចុងក្រោយនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅដឹកស្ត្រីម្នាក់នៅខាងផ្សារបឹងត្របែកផ្លាហ្សា ដោយនៅវេលាម៉ោង ៩ និង ៣៧នាទី ឈ្មោះ [redacted] លុច បានឆាតមកខ្លួនតាមតេឡេក្រាមលេខ ០៨៦ ៨៨៤ ៨៨៩ ដោយប្រើខ្លួនឱ្យទៅយកស្ត្រីម្នាក់នៅខាងមុខបឹងផ្សារផ្លាហ្សា ដោយឱ្យលេខទូរស័ព្ទ ០៩៨ ២២១ ៣១៥ ដើម្បីទំនាក់ទំនងទៅយកស្ត្រីម្នាក់នោះ ពេលទៅដល់ទីនោះ ខ្លួនបានឃើញស្ត្រីម្នាក់នោះកាន់ថង់ខ្មៅចំនួន ០១ ឡើងជិះ PASSAPP របស់ខ្លួន ខ្លួនក៏បានដឹកគាត់មកផ្ទះរបស់ឈ្មោះ [redacted] លុច ដែលនៅក្នុងបុរីប៉េងហួត ផ្លូវម៉ុងរិទ្ធី ពេលទៅដល់ស្ត្រីនោះបានចេញមកវិញ និងបានឱ្យខ្លួនដឹកទៅផ្សារបឹងត្របែកផ្លាហ្សាវិញ ដោយគាត់ប្រាប់ថា គាត់ផ្ញើម៉ូតូនៅទីនោះ ពេលដឹកស្ត្រីនោះខ្លួនលឺស្ត្រីនោះនិយាយទូរស័ព្ទពីរឿងជំពាក់លុយគេច្រើន។ ពេលទៅដល់ផ្សារបឹងត្របែកផ្លាហ្សា ស្ត្រីនោះពុំមានប្រាក់វាយ គាត់ក៏បានដើរទៅដូរលុយគេហើយយកមកឱ្យខ្លួនចំនួន ២០.០០០



Scanned with CamScanner

(ពីរម៉ឺន)រៀល ផ្ញើដឹក។ ក្រោយមកខ្លួនក៏បំបែកផ្លូវជាមួយគាត់ទៅ ខ្លួនក៏បន្តដឹកម៉ូយជាធម្មតា។ ចំពោះភិនភាគស្ត្រីនោះ មានស្តើង កម្ពស់ប្រហែល ១,៦២ សម្បុរស្រអែម សក់ទម្លាក់ក្រោមស្មា ពាក់អាវស ខោខ្មៅ និងពាក់មួក ខ្លួនមិនបានឃើញមុខទេ ដោយសារគាត់ពាក់ម៉ាស់។

-ជនជាប់ចោទឈ្មោះ [redacted] នី([redacted] NY) អវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធី ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា:** ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងពិនិត្យភស្តុតាងក្នុងសំណុំរឿង ពុំឃើញមានភស្តុតាងណាមួយធ្វើឱ្យជឿបានទេ ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកជាបានការដដែល សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លុច បានធ្វើសេចក្តីសន្និដ្ឋានការពារថា ពាក់ព័ន្ធការសួរដេញដោលចំពោះមុខអង្គសវនាការនេះ កូនក្តីខ្លួនបានឆ្លើយតាំងពីសមត្ថកិច្ចរហូតដល់អយ្យការ ចៅក្រមស៊ើបសួរ និងក្នុងពេលសវនាការនេះ បានឆ្លើយសារភាពថា គាត់មានមុខរបរផ្ញើអីវ៉ាន់ជាលក្ខណៈគ្រួសារ ពុំមានឧបករណ៍សម្រាប់ស្កេនអីវ៉ាន់ទេ ហើយឥវ៉ាន់ដែលសមត្ថកិច្ចឃាត់បាននោះជារូបចម្លាក់មិនមើលឃើញថា ខាងក្នុងមានរបស់អ្វីទេ ហើយពាក់ព័ន្ធនឹងបញ្ញើ គាត់បានទទួលភាគរយពីក្រុមហ៊ុនធំ។ ពាក់ព័ន្ធក្នុងរឿងនេះ គ្រាន់តែមានវិមតិសង្ស័យលើកូនក្តីខ្លួនតែប៉ុណ្ណោះ ដូចនេះ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទ **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នី([redacted] NY) បានធ្វើសេចក្តីសន្និដ្ឋានការពារថា** ក្នុងអង្គហេតុនេះមិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបានប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ដូចដែលឈ្មោះ [redacted] លុច បានចោទប្រកាន់នោះទេ ជាការអះអាងរបស់ភាគីតែម្ខាងតែប៉ុណ្ណោះ។ បន្ទាប់ពីសមត្ថកិច្ចបានបញ្ជូនឈ្មោះ [redacted] លុច រួមទាំងវត្ថុតាង មកកាន់នាយកដ្ឋានសន្តិសុខផ្ទៃក្នុងដើម្បីធ្វើការសាកសួរ ហើយឈ្មោះ [redacted] លុច បានឆ្លើយថា កញ្ចប់បញ្ញើនោះគឺកូនក្តីខ្លួន បានយកមកផ្ញើខ្លួនចេញទៅប្រទេស នូវែលសេឡង់។ ឈ្មោះ [redacted] លុច ជាអ្នកទទួលបញ្ញើ គួរណាស់តែមានការត្រួតពិនិត្យត្រឹមត្រូវជាមុនសិន មុននឹងយល់ព្រមទទួលអីវ៉ាន់បញ្ញើនោះពីអតិថិជន ប៉ុន្តែឈ្មោះ [redacted] លុច បានទទួលបញ្ញើពីកូនក្តីខ្លួនរួចរាល់ហើយទើបក្រុមមន្ត្រី X-Ray ប្រចាំនៅក្រុមហ៊ុន DHL Express(Cambodia) Ltd សាខាព្រៃទាបានត្រួតពិនិត្យស្កេនកញ្ចប់បញ្ញើមានផ្ទុកបង្កប់នូវសារធាតុញៀនខុសច្បាប់ នៅពេលក្រោយនោះទេ។ ក្នុងករណីនេះជាការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ដោយមិនទាក់ទងនឹងកូនក្តីខ្លួនឡើយ។ កូនក្តីខ្លួនមិនបានប្រព្រឹត្តនូវបទល្មើសដូចអ្វីដែលតំណាងអយ្យការធ្វើការចោទប្រកាន់នោះទេ។ សេចក្តីដូចបានជម្រាបជូនខាងលើ ស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់ទៅលើកូនក្តីខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] លុច បាននិយាយជាចុងក្រោយថា សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចខ្លួនពីបទចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ពិតជាមានអង្គហេតុ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃ



Scanned with CamScanner

ទី៣១ ខែមីនា ឆ្នាំ២០២២ ប្រាកដមែន។

២-ពិតជាមានអង្គហេតុ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] លុច ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] នី([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ប្រាកដមែន។

៣-អង្គហេតុ ប្រព្រឹត្តឡើងដោយជនជាប់ចោទ និងទីកន្លែងដូចខាងលើ មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្ម-ទណ្ឌ ដូចជាការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន តាមដីកាសន្និដ្ឋានស្ថាពរលេខ **២៩៣៩ អ.ឃ.គ** ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៩១៦ “ដ”ដ.ដ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

៤-ជនជាប់ចោទឈ្មោះ [redacted] លុច ឆ្លើយថា ខ្លួនជាអ្នកប្រកបមុខរបរ ជាអ្នកទទួលបញ្ញើទៅក្រៅប្រទេសជាលក្ខណៈគ្រួសារ ដោយខ្លួនទទួលបញ្ញើពីប្រទេសកម្ពុជា ផ្ញើទៅក្រៅប្រទេស ខ្លួនបានបង្កើតគេហទំព័រ(Facebook Pape) ឈ្មោះ Gofast Express ហើយទីតាំងដែលខ្លួនទទួលបញ្ញើពីអតិថិជនគឺធ្វើនៅផ្ទះដែលខ្លួនស្នាក់នៅតែម្តង ដោយពុំមានលើកផ្លាកអ្វីនោះទេ ហើយក៏ពុំមានចុះបញ្ជីត្រឹមត្រូវដែរ។ ក្រោយពីខ្លួនបានទទួលបញ្ញើពីអតិថិជនរួចមក ខ្លួនក៏យកបញ្ញើរបស់អតិថិជនទៅឱ្យក្រុមហ៊ុន **ហ្វារិក វើលវាយ អ៊ិចប្រេស** (FAREX WORLDWIDE EXPRESS) ហើយក្រុមហ៊ុននេះបានយកទៅផ្ញើបន្តឱ្យក្រុមហ៊ុន ឌីអិចប្រេស (DHL CAMBODIA) បន្តទៀត។

កាលពីថ្ងៃទី២៨, ២៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១០ព្រឹក មានស្ត្រីម្នាក់មិនស្គាល់ឈ្មោះ បានទូរ-ស័ព្ទលេខ(០៩៨ ២២១៣១៥) មកខ្លួន ដើម្បីសួរនាំអំពីការផ្ញើអីវ៉ាន់ចេញទៅប្រទេសក្រៅ ដោយបានសួរទីតាំងរបស់ខ្លួនដែលទទួលបញ្ញើ ហើយខ្លួនក៏បានប្រាប់ថា ខ្លួនស្នាក់នៅបុរីប៉េងហួត លើផ្លូវម៉ុងរិទ្ធី ហើយស្ត្រីនោះក៏បានឆ្លើយថា គាត់ស្នាក់នៅប៉េងហួតដែរ គឺនៅបុរីប៉េងហួតបឹងស្នោ គម្រោងទី៦ ចាំគាត់យកអីវ៉ាន់ទៅឱ្យដោយផ្ទាល់ដៃ។ លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្ត្រីម្នាក់នោះបានទូរស័ព្ទមកខ្លួនដោយប្រាប់ថា នឹងយកអីវ៉ាន់ទៅដាក់ផ្ញើហើយ។ លុះម៉ោងប្រហែល ៩ព្រឹក ស្ត្រីរូបនោះបានទូរស័ព្ទមកខ្លួនឱ្យទៅយកអីវ៉ាន់នៅម្តុំបឹងត្របែក ហើយខ្លួនក៏បានឱ្យអ្នករត់កង់បីឈ្មោះ រតនៈ ទៅយកគាត់ និងអីវ៉ាន់របស់គាត់។ ក្រោយមកម៉ោងប្រហែល ១១ព្រឹក ឈ្មោះ រតនៈ បានដឹកស្ត្រីម្នាក់នោះមកដល់ផ្ទះរបស់ខ្លួន រួចខ្លួនក៏បានយកអីវ៉ាន់របស់គាត់ទៅថ្លឹង រួមទាំងកេះក្រដាស់នោះផង មានទម្ងន់សរុបប្រហែល ១,៧៥គីឡូក្រាម។ លុះពេលថ្លឹងរួចហើយ ខ្លួនក៏បានបើកកេះក្រដាស់នោះដើម្បីមើលអីវ៉ាន់ជាក់ស្តែង។ ក្រោយពេលបើករួចមកក៏ឃើញមានអាវយឺតចំនួន ០១(មួយ) កន្សែងបង់កចំនួន ០១ (មួយ) ស្បែកជើងផ្ទាត់ ០១(មួយ)គូរ រូបចម្លាក់បាយ័នចំនួន ០១(មួយ) និងរូបចម្លាក់អង្គរវត្តចំនួន ០១(មួយ) ហើយពេលនោះខ្លួនពុំបាន ឬគាស់មើលអីវ៉ាន់នោះឱ្យបានល្អិតល្អន់ទេ ពីព្រោះខ្លាចខូចអីវ៉ាន់។ បន្ទាប់មកខ្លួនបានសរសេរវិក័យបត្រដោយបានសរសេររាយមុខអីវ៉ាន់និមួយៗ ចូលក្នុងវិក័យបត្រនោះ ដោយគិតតម្លៃចំនួន ០២(ពីរ)គីឡូក្រាម តម្លៃផ្ញើជាប្រាក់ចំនួន ១១៥(មួយរយដប់ប្រាំ)ដុល្លារអាមេរិក ហើយស្ត្រីនោះបានប្រាប់ខ្លួនឱ្យដាក់ឈ្មោះ ដាណេ ជាអ្នកផ្ញើ និងមានឈ្មោះអ្នកទទួលឈ្មោះ [redacted] XU មានអាសយដ្ឋាននៅប្រទេស NEW ZEALAND ដោយប្រើលេខទូរស័ព្ទ +៦៤០២២ ៦៤៦៧០៤៣។ ក្រោយពីបានទទួលប្រាក់រួច ខ្លួនបានឱ្យស្ត្រីម្នាក់នោះភ្ជាប់ TELEGRAM មកលេខទូរស័ព្ទខ្លួន ០៨៦ ៨៨៤ ៨៨៩ ក្រោយពីស្ត្រីនោះភ្ជាប់ TELEGRAM មកលេខទូរស័ព្ទខ្លួនផ្ទាល់ ក្រោយពេលស្ត្រីនោះបានភ្ជាប់កម្មវិធីរួចហើយ ខ្លួនបានឃើញលេខ TELEGRAM របស់គាត់ឈ្មោះ [redacted]NY បន្ទាប់មកខ្លួនក៏បានថតអីវ៉ាន់បានទទួលពីគាត់ រួចផ្ញើឱ្យគាត់តាម TELEGRAM តែម្តង។ បន្ទាប់មកខ្លួនបានទាក់ទងទៅបុគ្គលិកផ្នែកលក់



Scanned with CamScanner

របស់ក្រុមហ៊ុន ហ្វារិក វើលវាយ អ៊ិចប្រេស (FAREX WORLDWIDE EXPRESS) ឈ្មោះ [redacted] ធឿន ដើម្បីឱ្យគាត់ទទួលអីវ៉ាន់ ហើយឈ្មោះ [redacted] ធឿន បានប្រាប់ថា ចាំបាយហើយចាំឱ្យភ្នាក់ងារមកទទួល។ លុះដល់ម៉ោងប្រហែល ០២រសៀល បុគ្គលិកក្រុមហ៊ុន ហ្វារិក វើលវាយ អ៊ិចប្រេស(FAREX WORLDWIDE EXPRESS) បានទទួលអីវ៉ាន់ពីខ្លួននៅផ្ទះរបស់ខ្លួនផ្ទាល់។ លុះប្រហែលម៉ោង ៤រសៀល នាថ្ងៃខែឆ្នាំដដែល ឈ្មោះ [redacted] ធឿន បានផ្ញើបង្កាន់ដៃរបស់ក្រុមហ៊ុន DHL មកឱ្យខ្លួន ដោយនៅក្នុងបង្កាន់ដៃនោះមានលេខកូដសម្រាប់តាមដានអីវ៉ាន់ លុះប្រហែលម៉ោង ៥ល្ងាច ខ្លួនក៏បានផ្ញើបន្តទៅតេឡេក្រាមឈ្មោះ [redacted] NY ដែលជាម្ចាស់អីវ៉ាន់ ដែលចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសាររបស់ជនជាប់ចោទតែប៉ុណ្ណោះ ដែលតុលាការមិនអាចជឿបាន ដោយហេតុថា មុខរបរជាអ្នកទទួលបញ្ញើទៅក្រៅប្រទេសជាលក្ខណៈគ្រួសារ បង្កើតគេហទំព័រ(Facebook Pape) ឈ្មោះ Gofast Express ហើយទីតាំងដែលខ្លួនទទួលបញ្ញើពីអតិថិជនគឺធ្វើនៅផ្ទះដែលខ្លួនស្នាក់នៅតែម្ដង ដោយពុំមានលើកផ្លាកអ្វីនោះទេ ហើយក៏ពុំមានចុះបញ្ជីត្រឹមត្រូវដែរ ជាអំពើខុសច្បាប់។

៥-សាក្សីឈ្មោះ [redacted] រតន: បានឆ្លើយថា ខ្លួនមានមុខរបរ ជាអ្នករត់កង់បី កន្លងមកខ្លួនធ្លាប់បានទៅដឹក និងទទួលភ្ញៀវដែលមកផ្ញើអីវ៉ាន់តាមរយៈឈ្មោះ ពេជ្រ លុច បានចំនួន ០៤(បួន)ដង។ ចុងក្រោយនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅដឹកស្ត្រីម្នាក់នៅខាងផ្សារបឹងត្របែកផ្លាហ្សា ដោយនៅវេលាម៉ោង ៩ និង ៣៧នាទី ឈ្មោះ [redacted] លុច បានឆាតមកខ្លួនតាមតេឡេក្រាមលេខ ០៨៦ ៨៨៤ ៨៨៩ ដោយប្រើខ្លួនឱ្យទៅយកស្ត្រីម្នាក់នៅខាងមុខបឹងផ្សារផ្លាហ្សា ដោយឱ្យលេខទូរស័ព្ទ ០៩៨ ២២១ ៣១៥ ពិតប្រាកដមែន គប្បីតុលាការពិចារណា។

៦-សាក្សីឈ្មោះ [redacted] ឆ្នោត បានឆ្លើយថា ខ្លួនជាបុគ្គលិកផ្នែកដឹកជញ្ជូនរបស់ក្រុមហ៊ុន ហ្វារិក(FAREX) ដែលជាក្រុមហ៊ុនទទួលផ្ញើអីវ៉ាន់ទៅក្រៅប្រទេស។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៤ និង ០០នាទី ខាងផ្នែកលក់របស់ក្រុមហ៊ុនបានឱ្យខ្លួនទៅទទួលអីវ៉ាន់ពីឈ្មោះ [redacted] លុច ចំនួន ០១(មួយ)កញ្ចប់ ហើយខ្លួនក៏បានទៅជួបឈ្មោះ [redacted] លុច និងបានទទួលកញ្ចប់បញ្ញើដែលមានលេខកូដ WAYBILL 1835241111 ពីគាត់ ពេលនោះគាត់បានបើកបង្ហាញឱ្យមើលឃើញមាន កន្សែងចំនួន ០២ ស្បែកជើងស្រី ០១គូ និងរូបចម្លាក់ប្រាសាទអង្គរវត្ត ពណ៌ទឹកប្រាក់ចំនួន ០១ និងបន្ទោងឈើចំនួន ០១បន្ទះ បានបង្ហាញឱ្យឃើញថា ឈ្មោះ ពេជ្រ លុច ពិតជាបានផ្ញើអីវ៉ាន់ទៅក្រុមហ៊ុនដឹកជញ្ជូន ហ្វារិក(FAREX) គប្បីតុលាការពិចារណា ។

៧-សាក្សីឈ្មោះ [redacted] សុធា បានឆ្លើយថា ខ្លួនបានប្រកបមុខរបរ ទទួលផ្ញើអីវ៉ាន់ទៅក្រៅប្រទេស ជូនអតិថិជនដោយធ្វើជាលក្ខណៈគ្រួសារ ខ្លួនពុំមានអាជ្ញាប័ណ្ណទេ។ រាល់ការទទួលផ្ញើអីវ៉ាន់ពីអតិថិជនទាំងអស់ គឺខ្លួនមានហ្វេសប៊ុកផេកឈ្មោះ GO FAST EXPRESS និងមានលេខទូរស័ព្ទ ០៩៩ ៨៨៤ ៨៨៩ និងលេខ ០៨៦ ៨៨៤ ៨៨៩ សម្រាប់ទទួលផ្ញើទៅក្រៅប្រទេស។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានឃើញឈ្មោះ ពេជ្រ លុច បានទំនាក់ទំនងជាមួយអតិថិជនស្ត្រីម្នាក់ដែលយកអីវ៉ាន់មកផ្ញើទៅក្រៅប្រទេសមែន គប្បីតុលាការពិចារណា។

៨-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានទោសលើជនជាប់ចោទឈ្មោះ [redacted] លុច ថា ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងពិនិត្យភស្តុតាងក្នុងសំណុំរឿង ពុំឃើញមានភស្តុតាងណាមួយធ្វើឱ្យជឿបានទេ ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកជាបានការដដែល សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា។

៩-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លុច បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ពាក់ព័ន្ធក្នុងរឿងនេះគ្រាន់តែមានវិមតិសង្ស័យលើកូនក្ដីខ្លួនតែប៉ុណ្ណោះ ដូចនេះ សុំឱ្យតុលាការ សម្រេចឱ្យកូនក្ដីខ្លួនរួចខ្លួនពីបទ **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ គប្បីតុលាការពិចារណា។



Scanned with CamScanner

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នី ([redacted] NY) បានធ្វើសេចក្តីសន្និដ្ឋានការពារថា ឈ្មោះ [redacted] លុច ជាអ្នកទទួលបញ្ញើ បានត្រួតពិនិត្យត្រឹមត្រូវមុននឹងយល់ព្រមទទួលអីវ៉ាន់បញ្ញើនោះពីអតិថិជន ប៉ុន្តែឈ្មោះ ពេជ្រ លុច បានទទួលបញ្ញើពីកូនក្តីខ្លួនរួចរាល់ហើយទើបក្រុមមន្ត្រី X-Ray ប្រចាំនៅក្រុមហ៊ុន DHL Express(Cambodai) Ltd សាខាព្រៃទាបានត្រួតពិនិត្យស្កេនកញ្ចប់បញ្ញើមានផ្ទុកបង្កប់នូវសារធាតុញៀនខុសច្បាប់នៅ ពេលក្រោយនោះទេ។ ក្នុងករណីនេះជាការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ដោយមិនទាក់ទងនឹងកូនក្តីខ្លួនឡើយ។ កូនក្តីខ្លួនមិនបានប្រព្រឹត្តនូវបទល្មើសដូចអ្វីដែលតំណាងអយ្យការធ្វើការចោទប្រកាន់នោះទេ។ សេចក្តីដូចបានជម្រាបជូនខាងលើ ស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់ទៅលើកូនក្តីខ្លួន គប្បីតុលាការពិចារណា ។

១១-វត្ថុចាប់យកដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted] លុច កេសក្រដាស់ចំនួន ០១ ដែលមានបិទកំណត់ហេតុបើកកេសវត្ថុតាង ធ្វើតេស្ត ថ្លឹង និងវេចខ្ចប់ ជាសារធាតុញៀន មេតំហ្វេតាមីន មានទម្ងន់សរុប ១០៤,៧០ (មួយរយបួនក្បៀសចិតសិប)ក្រាម ដែលមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៦៦០ រ.វ.ត ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ របស់ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យកសាលាដំបូងរាជធានីភ្នំពេញ និងផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ **៣៦៤៩៦/២២** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលទ្ធផល វិជ្ជមាន វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ **៧៥,៥៨%**(ចិតសិបប្រាំកណ្តក់សញ្ញាហាសិបប្រាំបីភាគរយ) នាំឱ្យមានបរិមាណភាពសុទ្ធ **១០៤,៧០**ក្រាម X **៧៥,៥៨%** ស្មើនឹង **៧៩,១៣២២ (ចិតសិបប្រាំបួនក្បៀសមួយពាន់បីរយម្ភៃពីរ)**ក្រាម ត្រូវរឹបអូស និងបំផ្លាញចោលតាមមាត្រា ៩៣ និង មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២-វត្ថុចាប់យកមាន៖

ក-ចិញ្ចៀនលោហៈធាតុពណ៌លឿងស្លេក ចំនួន ០១វង់។

ខ-នាឡិកាដៃចំនួន ០១គ្រឿង។

គ-ប្រាក់ដុល្លារចំនួន ១០០(មួយរយ)ដុល្លារអាមេរិក។

ឃ-ទូរស័ព្ទដៃម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១គ្រឿង។

គប្បីរឹបអូសជាទ្រព្យសម្បត្តិរដ្ឋតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

១៣-វត្ថុចាប់យកមាន៖

ក-កាបូបដាក់ប្រាក់ចំនួន ១(មួយ)។

ខ-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ ពេជ្រ លុច ។

គ-ប័ណ្ណបើកបររថយន្តចំនួន ០១។

ឃ-ប័ណ្ណចាក់វ៉ាក់សាំងកូវីដចំនួន ០១។

ង-កាតធនាគារ ABA ចំនួន ០១។

ច-កាតធនាគារ អេស៊ីលីដា ចំនួន ០១។

ឆ-កាតធនាគារសហពាណិជ្ជកម្ម ក.អ ចំនួន ០១។

ជ-កាតធនាគារ MAY BANK ចំនួន ០១។

ឈ-កាតធនាគារ J.Trust BANK ចំនួន ០១។

ញ-កាបូបយួរដៃចំនួន ០១។



Scanned with CamScanner

ច-ឯកសារមួយចំនួន ។

មិនមែនជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីប្រគល់ទៅឱ្យម្ចាស់ដើមវិញតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៤-វត្ថុចាប់យកជា រថយន្តម៉ាក RANG ROVER ពណ៌ស ឆ្នាំ២០១៤ ពាក់ផ្លាកលេខកម្ពុជា H.S.2021 ចៅក្រមស៊ើបសួរបានសម្រេចប្រគល់ឱ្យម្ចាស់ដើមគ្រប់គ្រងជាបណ្ដោះអាសន្ន តាមដីកាសម្រេចប្រគល់វត្ថុចាប់យកឱ្យទៅម្ចាស់ដើមវិញលេខ ៣១៤(ង)ព្រ.ទ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ គប្បីតុលាការសម្រេចប្រគល់ឱ្យទៅម្ចាស់វិញតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

១៥-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៤៥១(ង)ង.ច.ន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អស់អានុភាពអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

១៦-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន ជនជាប់ចោទឈ្មោះ [redacted] ទី ([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ នៅមណ្ឌលអប់រំទី២(មខ២)ព្រៃស នៃក្រសួងមហាផ្ទៃ តាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

១៧-អំពើប្រព្រឹត្តឡើងរបស់ជនជាប់ចោទឈ្មោះ [redacted] លុច និងឈ្មោះ [redacted] ទី([redacted] NY) គឺប្រព្រឹត្តឡើងជាប្រព័ន្ធដោយមានអ្នកផ្គត់ផ្គង់គ្រឿងញៀន និងអ្នកដឹកជញ្ជូនគ្រឿងញៀនបន្តទៅក្រៅប្រទេស ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ ជាពិសេសធ្វើឱ្យប៉ះពាល់សុខភាពប្រជាពលរដ្ឋ គប្បីតុលាការពិចារណា។

១៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] លុច ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ទី([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ ពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៩-ជនជាប់ចោទឈ្មោះ [redacted] លុច បាននិយាយជាសម្តីចុងក្រោយថា សុំឱ្យតុលាការសម្រេចឱ្យខ្លួន រួចខ្លួនពីបទចោទ គប្បីតុលាការពិចារណា។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] លុច ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] ទី([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ម្នាក់ៗចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ពីបទៈ **ដឹកជញ្ជូនដោយ**ខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៤៥១"ង"ង.ច.ន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អស់អានុភាពអនុវត្តតាមអំណាចសាលក្រមនេះ។

៣-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន ជនជាប់ចោទឈ្មោះ [redacted] ទី ([redacted] NY) ភេទស្រី កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ នៅមណ្ឌលអប់រំទី២(មខ២)ព្រៃស នៃក្រសួងមហាផ្ទៃ តាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។



Scanned with CamScanner

៤-វត្ថុចាប់យកជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនមានទម្ងន់ ១០៤,៧០(មួយរយបួនក្បៀសចិតសិប)ក្រាម មានកំរិតភាពសុទ្ធ ១០៤,៧០ គុណ ៧៥,៥៨% ស្មើនឹង ៧៩, ១៣២២ក្រាម ត្រូវរឹបអូសបំផ្លាញចោលតាមមាត្រា ៩៣ និង មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥-វត្ថុចាប់យកមាន៖**

ក-ចិញ្ចៀនលោហៈធាតុពណ៌លឿងស្តេក ចំនួន ០១វង់។

ខ-នាឡិកាដៃចំនួន ០១គ្រឿង។

គ-ប្រាក់ដុល្លារចំនួន ១០០(មួយរយ)ដុល្លារអាមេរិក។

ឃ-ទូរស័ព្ទដៃម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១គ្រឿង។

**ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។**

**៦-វត្ថុចាប់យកមាន៖**

ក-កាបូបដាក់ប្រាក់ចំនួន ១(មួយ)។

ខ-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ ពេជ្រ លុច ។

គ-ប័ណ្ណបើកបររថយន្តចំនួន ០១។

ឃ-ប័ណ្ណចាក់វ៉ាក់សាំងកូវីដចំនួន ០១។

ង-កាតធនាគារ ABA ចំនួន ០១។

ច-កាតធនាគារ អេស៊ីលីដា ចំនួន ០១។

ឆ-កាតធនាគារសហពាណិជ្ជកម្ម ក.អ ចំនួន ០១។

ជ-កាតធនាគារ MAY BANK ចំនួន ០១។

ឈ-កាតធនាគារ J.Trust BANK ចំនួន ០១។

ញ-កាបូបស្ពាយដៃចំនួន ០១។

ច-ឯកសារមួយចំនួន ។

**ត្រូវប្រគល់ទៅឱ្យម្ចាស់ដើមវិញ ។**

៧-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លុច កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ទី([redacted] NY) និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃចន្ទ ១០រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]